ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈសង្ឃនាយក
នៃព្រះរាជាណាចក្រកម្ពុជា
លេខ: ០៦៥/២០ ស.ន.ក.ជ

# សេចក្ដីប្រកាស

## ស្ដីពីការទប់ស្កាត់ការឆ្លងវីរុសកូវីដ១៩
## ប្រគេនចំពោះព្រះមេគណ ព្រះគ្រូអនុគណ ព្រះចៅអធិការគ្រប់វត្ត
## និងជូនចំពោះពុទ្ធបរិស័ទទូទាំងព្រះរាជាណាចក្រកម្ពុជា

ដោយមើលឃើញតម្លៃព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ និងកិច្ចការងារសង្គមដែលព្រះពុទ្ធសាសនាត្រូវចូលរួមចំណែក ថ្មីៗនេះវីរុសកូវីដ១៩ បាននិងកំពុងរាតត្បាត នៅលើសកលលោកប្រមាណជាង១០០ប្រទេស រួមទាំងប្រទេសកម្ពុជាយើងផងដែរ។ ដោយឡែកនៅប្រទេសកម្ពុជាយើង រាជរដ្ឋាភិបាលបានរកឃើញអ្នកបានឆ្លងជំងឺនេះ ហើយក៏បានរៀបចំវិធីទប់ស្កាត់ការរីករាលដាល ដោយស្ថាប័នជំនាញសុខាភិបាលជាតិ និងអន្តរជាតិ រួមទាំងអង្គការយូនីសេហ្វផងដែរ។

ដើម្បីចូលរួមចំណែកជាមួយការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល **គណៈសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា** សូមអំពាវនាវដល់ ព្រះមេគណ ព្រះគ្រូអនុគណ ព្រះចៅអធិការគ្រប់វត្ត និងពុទ្ធបរិស័ទគ្រប់មជ្ឈដ្ឋានទូទាំងប្រទេសដូចខាងក្រោម៖

១. ត្រូវស្វែងយល់អំពីវីរុសកូវីដ១៩ នេះ តាមរយៈការមើល ស្ដាប់ និងសិក្សានូវសម្ភារៈអប់រំ ដូចជាស្ពត វីដេអូ វិទ្យុ រួមទាំងលិខិតប័ណ្ណផ្សព្វផ្សាយ ដែលផលិតដោយ ស្ថាប័នសុខាភិបាលជាតិ-អន្តរជាតិ និងអង្គការយូនីសេហ្វ។

២. នៅថ្ងៃចន្ទ ១៥រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០ នៅវេលាម៉ោង ៣:០០ នាទី រសៀល ខាងមុខនេះ សូមព្រះមេគណ ព្រះគ្រូអនុគណ ព្រះចៅអធិការគ្រប់វត្ត ទូទាំងព្រះរាជាណាចក្រកម្ពុជា ទូងស្គរឲ្យបានព្រមគ្នា និងប្រកាសសូត្រព្រះធម៌មាន **រតនសុត្តារម្ភៈ និង រតនសូត្រ** ជាដើម ឲ្យបានកងរំពងគ្រប់វត្តអារាម ស្របតាមកិច្ចដែលព្រះមហាអានន្ទត្ថេរដ៏មានអាយុ បានតាំងចិត្តប្រកបដោយមេត្តាចំពោះសព្វសត្វទាំងអស់ រួចហើយស្វាធ្យាយ នៅក្រុងវេសាលី កាលដែលព្រះអង្គគង់ធរមាននៅឡើយ ដែលមានក្នុងសុត្តន្តបិដក ខុទ្ទកនិកាយលេខ ៥២ ដើម្បីកំចាត់បង់នូវភយន្តរាយទាំងឡាយដែលកើតអំពីរោគ អមនុស្ស និងទុរភិក្សជាដើម ឲ្យអន្តរធានបាត់ដោយឆាប់រហ័សក្នុងពេលនោះឯង។ តែមិនចាំបាច់ប្រមូលមនុស្សម្នា ឲ្យជួបជុំគ្នាច្រើនពេកទេ ជាពិសេសហាមឃាត់អ្នកដែលមានការពាក់ព័ន្ធជាមួយអ្នកបានឆ្លងវីរុសកូវីដ១៩ នេះ។

Scanned with CamScanner

៣. ត្រូវបន្តផ្សព្វផ្សាយតាមគ្រប់រូបភាព ទាំងតាមរយៈទេសនា ចែកចាយឯកសារអប់រំ ដែលផលិតដោយស្ថាប័នសុខាភិបាលជាតិ-អន្តរជាតិ និងអង្គការយូនីសេហ្វ ដល់គ្រប់ពុទ្ធបរិស័ទចំណុះជើងវត្តទៅតាមគ្រប់មធ្យោបាយដែលមាន។

៤. ត្រូវប្រកាន់យកនូវការអនុវត្តអនាម័យស្អាតជានិច្ច និងសុវត្ថិភាពចំណីអាហារគ្រប់ពេល។

៥. ប្រសិនបើជួបអ្នកជំងឺដែលមានអាការៈដូចជា៖ គ្រុនក្តៅ ក្អក កណ្តាស់ ផ្តាសាយ ហៀរសំបោរ ឬឈឺបំពង់ក ត្រូវជួយបញ្ជូនទៅកាន់មណ្ឌលសុខភាពដែលនៅជិតបំផុត ដើម្បីទទួលពិនិត្យ និងព្យាបាលជាបន្ទាន់។

**គណៈសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា** សង្ឃឹមយ៉ាងមុតមាំថា ព្រះមេគណ ព្រះគ្រូអនុគណ ព្រះចៅអធិការគ្រប់វត្ត ព្រះសង្ឃ និងពុទ្ធបរិស័ទគ្រប់មជ្ឈដ្ឋាន នឹងអនុវត្តតាមសេចក្តីអំពាវនាវនេះដោយសេចក្តីជ្រះថ្លា និងយកចិត្តទុកដាក់ខ្ពស់បំផុត។

**អរោគ្យា បរមា លាភា** ការមិនមានរោគជាលាភដ៏ប្រសើរ ! ៤

ថ្ងៃចន្ទ ៨ រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ២០២០

**គណៈសង្ឃនាយក**

ព្រះរាជាណាចក្រកម្ពុជា

គណៈសង្ឃនាយក

នន្ទ-ង៉ែត

Scanned with CamScanner